# ការបង្រៀនអំពីក្រឹត្យវិន័យនៃដង្វាយមួយភាគក្នុងដប់របស់ព្រះអង្គសង្គ្រោះ

សូមសិក្សាធនធានខាងក្រោម ដោយរកមើលអ្វីដែលអាចលើកទឹកចិត្តអ្នក ឬអ្នកដទៃឲ្យគោរពប្រតិបត្តិតាមក្រឹត្យវិន័យនៃដង្វាយមួយភាគក្នុងដប់ ។

ព្រះគម្ពីរ ៖

ម៉ាឡាគី ៣:៨–១០; យ៉ូហាន ៧:១៧; គោលលទ្ធិ និងសេចក្ដីសញ្ញា ១១៩:៥–៧

សេចក្ដីថ្លែងការណ៍ និងធនធានផ្សេងទៀត ៖

ប្រធាន ស្ទើវីន ជេ ឡាន់ ប្រធានក្រុមយុវជនទូទៅ បានបង្រៀន ៖



នៅពេលយុវវ័យថ្វាយដង្វាយមួយភាគដប់ពេញលេញ ពួកគេបង្កើតទំនាក់ទំនងមួយជាមួយនឹងព្រះវរបិតាសួគ៌ដែលនឹងបន្តជារៀងរហូត ។ រាល់ពេលដែលពួកគេគោរពបទបញ្ញត្តិនោះ ហើយថ្វាយដង្វាយ នោះចំណងថ្មីមួយនៃការលះបង់ និងទំនាក់ទំនងបានបង្កើតឡើង ។ ( ស្ទើវីន ជេ ឡាន់ « Seminary, Institute, and Other Things that Work » [ សុន្ទរកថាថ្លែងនៅក្នុងការចាក់ផ្សាយការបំពាក់បំប៉នប្រចាំឆ្នាំសម្រាប់ថ្នាក់សិក្ខាសាលា & ថ្នាក់វិទ្យាស្ថាននាថ្ងៃទី ២៧ ខែ មករា ឆ្នាំ ២០២៣ ] broadcasts.ChurchofJesusChrist.org )

*ដើម្បីកម្លាំងនៃយុវជន ៖ សេចក្ដីណែនាំសម្រាប់ធ្វើការជ្រើសរើស* ទូន្មាន ៖

> សូមបង្ហាញសេចក្ដីស្រឡាញ់ចំពោះព្រះ ដោយការគោរពតាមព្រះបញ្ញត្តិរបស់ទ្រង់ ។ . . .
>
> . . . នៅពេលអ្នកតមអាហារ និងថ្វាយដង្វាយមួយភាគក្នុងដប់ និងដង្វាយផ្សេងៗ នោះអ្នកបង្ហាញព្រះថា កិច្ចការរបស់ទ្រង់សំខាន់ចំពោះអ្នកជាងសម្ភារផ្សេងៗ ។ ( *ដើម្បីកម្លាំងនៃយុវជន ៖ សេចក្ដីណែនាំសម្រាប់ធ្វើការជ្រើសរើស* [ ឆ្នាំ ២០២២ ] ទំព័រ ១១–១២ )

ពេលកំពុងបម្រើជាសមាជិកនៃពួកចិតសិបនាក់ អែលឌើរ ស្ទែនលី ជី អេលីស បានពន្យល់ ៖



តើយើងមាន *ជំនឿ* ដើម្បីទុកចិត្តលើការសន្យា [ របស់ព្រះអម្ចាស់ ] ដែរឬទេ ទាក់ទងនឹងដង្វាយមួយភាគក្នុងដប់ថា ៩០ ភាគរយនៃប្រាក់ចំណូល *យើងរួមទាំងជំនួយរបស់ព្រះអម្ចាស់* យើងបានច្រើនជាង ១០០ ភាគរយ *តែម្យ៉ាងទៀត* ? ( ស្ទែនលី ជី អេលីស « Do We Trust Him? Hard Is Good » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៧ ទំព័រ ១១៤ )

អែលឌើរ ដេវីឌ អេ បែដណា ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានបង្រៀន ៖



ជាញឹកញាប់ នៅពេលយើងបង្រៀន និងថ្លែងទីបន្ទាល់អំពីក្រឹត្យវិន័យនៃដង្វាយមួយភាគក្នុងដប់ យើងសង្កត់ធ្ងន់លើពរជ័យខាងសាច់ឈាមដែលទទួលបានភ្លាមៗ អស្ចារ្យ ហើយងាយមើលដឹង ។ ប្រាកដណាស់ ពរជ័យដូច្នោះកើតមានមែន ។ ប៉ុន្តែពរជ័យផ្សេងៗមួយចំនួនដែលយើងទទួលនៅពេលយើងគោរពបញ្ញត្តិនេះគឺសំខាន់ តែតូចៗ ។ . . .

ឧទាហរណ៍ ពរជ័យដ៏មានតម្លៃ និងមានសារៈសំខាន់ដែលយើងទទួល គឺអំណោយទានខាងវិញ្ញាណនៃការដឹងគុណ ដែលជួយយើងអរគុណដល់អ្វីៗដែលយើងមាន រួចទប់បំណងដែលយើងចង់បានវិញ ។ . . .

> ពេលខ្លះ យើងសូមព្រះឲ្យមានជោគជ័យ ហើយទ្រង់ផ្ដល់ឲ្យយើងនូវកម្លាំងខាងរូបកាយ និងវិញ្ញាណ ។ យើងអាចនឹងសូមឲ្យមានភាពបម្រុងចម្រើន ហើយយើងទទួលនូវទស្សនវិស័យទូលំទូលាយ និងការអត់ធ្មត់ច្រើន ។ ( ដេវីឌ អេ បែដណា « The Windows of Heaven » *Liahona* ខែ វិច្ឆិកា ឆ្នាំ ២០១៣ ទំព័រ ១៧–១៨ )

ម៉ារី ហ្វីលឌីង ស្ម៊ីធ គឺជាស្ត្រីមេម៉ាយរបស់ ហៃរុម ស្ម៊ីធ និងជាម្ដាយរបស់ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ ។ ពេលមាននរណាម្នាក់ផ្ដល់យោបល់ថា នាងក្រពេកមិនគួរគោរពតាមក្រឹត្យវិន័យនៃដង្វាយមួយភាគក្នុងដប់ទេ នោះនាងបានឆ្លើយតបថា ៖

> តើអ្នកនឹងបដិសេធពរជ័យខ្ញុំទេ ? . . . ខ្ញុំថ្វាយដង្វាយមួយភាគក្នុងដប់ មិនគ្រាន់តែដោយសារវាជាក្រឹត្យវិន័យរបស់ព្រះប៉ុណ្ណោះទេ ប៉ុន្តែដោយសារខ្ញុំពឹងនឹងទទួលបានពរជ័យដោយថ្វាយដង្វាយមួយភាគក្នុងដប់ ។ ( ម៉ារី ហ្វីលឌីង ស្ម៊ីធ បានដកស្រង់ដោយ យ៉ូសែប អេហ្វ ស្ម៊ីធ នៅក្នុង Conference Report ខែ មេសា ឆ្នាំ ១៩០០ ទំព័រ ៤៨ )

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© by Intellectual Reserve, Inc. All rights reserved.

PD80007812_258_412-1